**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**
លេខ:.....១៩៤/២០.........ក.ប/អ.ក/អ.ធ.ក/ព.ក

**ជម្រាបមក**
**លោក ម្ចាស់ ឬនាយកក្រុមហ៊ុន រុង តេង (ខេមបូឌា) អ៊ិនស្តេកសិន ឯ.ក**

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត
**យោង** ៖ លិខិតលេខ ២០០៥១៩៦៤៩៩ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ របស់ក្រុមហ៊ុន រុង តេង (ខេមបូឌា) អ៊ិនស្តេកសិន ឯ.ក។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក ម្ចាស់ ឬនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣៧នាក់ (ស្រី ២៣នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ៤៣នាក់ (ស្រី ២៦នាក់) រយៈពេលចំនួន៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។ ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោក ម្ចាស់ ឬនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោក ម្ចាស់ ឬនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ។

អាស្រ័យដូចនេះ សូម **លោក ម្ចាស់ ឬនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក ម្ចាស់ ឬនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ អង្គារ ៥កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០
**ត.ប. រដ្ឋមន្ត្រី**
**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**អ៊ុក_ចាន់ធួ**

ចម្លងជូន:
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលរាជធានីភ្នំពេញ